# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម

០៧-៤-២០០៦ -ព្រះរាជក្រម នស/រកម/០៤០៦/០០៩ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី ២១២៣

### ២~ព្រះរាជក្រឹត្យ

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៤៧ ស្តីពីការប្រោសព្រះរាជទាន ចំពោះ លោក Fumiaki TAKAHASHI នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ២១៥៨

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៤៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ាង អ៊ីនឆាង** ( YANG YINCHANG ) ជនជាតិចិនកើតនៅខេត្ត គុយចូវ ប្រទេសចិន ២១៥៩

០២-៤-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៤០៦/១៥២ ស្តីពីការតែងតាំងគណៈគ្រប់គ្រងពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ២១៦០

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១១ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៦១

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១២ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៦២

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១៣ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៦៤

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១៤ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៦៥

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១៥ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៦៦

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១៦ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៦៧

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១៧ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៦៩

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១៨ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៧០

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២១៩ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៧១

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២២០ អនក្រ.តត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៧២

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២២១ អនក្រ.គត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៧៣

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២២២ អនក្រ.គត ស្តីពីការសំរួលភារកិច្ចមន្ត្រីរាជការ ២១៧៤

០៥-៤-២០០៦ -អនុក្រឹត្យលេខ ២២៣ អនក្រ.គត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ២១៧៥

០៦-៤-២០០៦ -អនុក្រឹត្យលេខ ២២៤ អនក្រ.គត ស្តីពីការជូនមេដាយការងារ ២១៧៧

០៦-៤-២០០៦ -អនុក្រឹត្យលេខ ២២៥ អនក្រ.គត ស្តីពីការជូនមេដាយការងារ ២១៧៩

## III-ការងារបណ្តាក្រសួង

### ១-ផ្នែកការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

០៧-៤-២០០៦ -ប្រកាសលេខ ៣៩១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **វ៉ាន់គូ អ៊ិនដាសស្ត្រៀល** បង្កើតរោងចក្រ " កាត់ដេរ ប៉ាក់ និងបោះពុម្ពសម្លៀកបំពាក់ " ដែលមាន ឈ្មោះថា " វ៉ាន់គូ អ៊ិនដាសស្ត្រៀល " ២១៨១

០៧-៤-២០០៦ -ប្រកាសលេខ ៣៩២ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ម៉េង តុង ហ្គាមេន មេនូហ្វេកធើរី** បង្កើតរោងចក្រ " កាត់ដេរ ប៉ាក់ និងបោះពុម្ពសម្លៀកបំពាក់ " ដែលមាន ឈ្មោះថា " ម៉េង តុង ហ្គាមេន មេនូហ្វេកធើរី " ២១៨៣

១១-៤-២០០៦ -ប្រកាសលេខ ៤០៩ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន **ខ្មែរ លេចិច** បង្កើតរោងចក្រ " កែច្នៃ និងផលិតជ័រកៅស៊ូក្រេប " ដែលមានឈ្មោះថា " ខ្មែរ លេចិច " ២១៨៥

### ២-ផ្នែកការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

០៣-៣-២០០៦ -លិខិតលេខ ៦៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) វ៉ាយអឹ ទៀនធី គីធីវ៉ាយ អិលធីឌី** ២១៨៧

០៣-៣-២០០៦ -លិខិតលេខ ៦៥៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីនខន-ទេនឈ័រ (ខេមបូឌា)** ២១៨៩

០៣-៣-២០០៦ -លិខិតលេខ ៦៥៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **តាវ ឈីវអៀន ខូ អិលធីឌី (ធី.ស៊ី.អ៊ី)** ២១៩១

០៣-៣-២០០៦ -លិខិតលេខ ៦៥៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អិម.អេស.អេស** ២១៩៣

០៦-៣-២០០៦ -លិខិតលេខ ៦៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សេសាន ឌីវេឡុបមេន & អ៊ីមផត អិចផត** ២១៩៥

០៦-៣-២០០៦ -លិខិតលេខ ៦៦៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីស្ត ខូសថ៍ ហ្វើធីឡាយហ្ស៊ែន** ២១៩៧

០៦-៣-២០០៦ -លិខិតលេខ ៦៦៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **មើលខម លីមីធិត** ២១៩៩

០៦-៣-២០០៦ -លិខិតលេខ ៦៦៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយអិនខប អ៊ិនធើណេសិន ណល ខូ អិលធីឌី** ២២០១

០៧-៣-២០០៦ -លិខិតលេខ ៦៧០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ចាង កុង គ្រុប** ២២០៣

០៧-៣-២០០៦ -លិខិតលេខ ៦៧២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេ យូ មីនីរ៉ល ភីធីអ៊ាយ អិលធីឌី** ២២០៥

០៧-៣-២០០៦ -លិខិតលេខ ៦៧៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ដាយហ្វូ ខបភើរេសិន** ២២០៧

០៧-៣-២០០៦ -លិខិតលេខ ៦៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ធី.អាយ.ស៊ី** ២២០៩

០៧-៣-២០០៦ -លិខិតលេខ ៦៧៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្ទឹងត្រែង ប៊ីយូធី** ២២១១

០៧-៣-២០០៦ -លិខិតលេខ ៦៧៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឈុន ថាន់ ហេង គ្រុប** ២២១៣

០៧-៣-២០០៦ -លិខិតលេខ ៦៨១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ី តី អិម ខូ អិលធីឌី** ២២១៥

០៧-៣-២០០៦ -លិខិតលេខ ៦៨៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស្តារជីស ខូ អិលធីឌី** ២២១៧

០៧-៣-២០០៦ -លិខិតលេខ ៦៨៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ណូគា ថាយថូលេកេនេ អយ** ២២១៩

០៧-៣-២០០៦ -លិខិតលេខ ៦៨៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ីក ជ្រ. ឡូតធើរ** ២២២០

០៧-៣-២០០៦ -លិខិតលេខ ៦៨៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ផៅវ៉ាំរ ផម គ្រុប** ២២២២

០៧-៣-២០០៦ -លិខិតលេខ ៦៩០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) ម៉ាល់ធី វ៉ាយធី មីន សេនធ័រ** ២២២៤

# ព្រះរាជក្រម

នស/រកម/០៤០៦/០០៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររជ្ជរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យច្បាប់នេះឱ្យទាន់តាមកាលកំណត់របស់មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខានៅសឹង្ហបុរី នាថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

នស/រកម.០៤០៦.០១៣ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ហត្ថលេខា**

**ស ខេង**

លេខ: ១៦០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**

# កិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងតំបន់
# ស្តីពី
# ការប្រយុទ្ធប្រឆាំងនឹងអំពើប្លន់នាវានិងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី

ភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងនេះ

មានការព្រួយបារម្ភអំពីការកើនឡើងនូវអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធក្នុងដែនសមុទ្រអាស៊ី

ដោយមានការយកចិត្តទុកដាក់លើការកើនឡើងនូវអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធនៅក្នុងដែនសមុទ្រអាស៊ី

ដោយមានការទទួលស្គាល់នូវសារសំខាន់នៃសុវត្ថិភាពនាវា រាប់បញ្ចូលទាំងនាវិក ដែលប្រើប្រាស់សិទ្ធិធ្វើនាវាចរណ៍ ដែលមានចែងក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៨២ ដែលហៅកាត់ថា "ច្បាប់សមុទ្រ"

ដើម្បីពង្រឹងកាតព្វកិច្ចរដ្ឋទាំងឡាយ ក្នុងកិច្ចសហការទប់ស្កាត់ និង បង្រ្កាបអំពើប្លន់នាវាដែលកំណត់ក្នុងច្បាប់សមុទ្រ

យោងតាម "សេចក្តីប្រកាសក្រុងតូក្យូ" ចុះខែមិនា ឆ្នាំ ២០០០ "បញ្ហាប្រឈមក្នុងការប្រឆាំងអំពើប្លន់នាវានៅអាស៊ី" ចុះខែមេសា ឆ្នាំ ២០០០ និង "ផែនការសកម្មភាពគំរូក្រុងតូក្យូ" ចុះខែមេសា ឆ្នាំ ២០០០

តាមការកត់សំគាល់នៃសេចក្តីសំរេចសម្ពហភាពដែលបានអនុម័តក្នុងមហាសន្និបាតអង្គការសហប្រជាជាតិ និងសេចក្តីសំរេចសម្ពហភាព និង អនុសាសន៍ទាក់ទិនទាំងឡាយដែលបានអនុម័តដោយអង្គការអន្តរជាតិទទួលបន្ទុកកិច្ចការសមុទ្រ

ដោយការយកចិត្តទុកដាក់លើសារសំខាន់នៃកិច្ចសហការអន្តរជាតិ និងតាមតម្រូវការចាំបាច់នៃការពង្រីកកិច្ចសហការ និងការសំរបសំរួលក្នុងតំបន់ រវាងរដ្ឋទាំងអស់ដែលរងផលប៉ះពាល់ពីបទល្មើសនេះនៅ ក្នុងទ្វីបអាស៊ី ក្នុងគោលបំណងទប់ស្កាត់ និងបង្ក្រាបអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធនៅក្នុងដែនសមុទ្រអាស៊ីអោយមានប្រសិទ្ធភាពខ្ពស់

ដោយមានការជឿជាក់ថាការចែករំលែកព័ត៌មាន និងការកសាងសមត្ថភាពក្នុងចំណោមរដ្ឋភាគីហត្ថលេខី នឹងផ្តល់វិភាគទានសំខាន់ដល់ការទប់ស្កាត់ និងការបង្ក្រាបអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធនៅក្នុងដែនសមុទ្រអាស៊ី

ដោយមានការអះអាងថា ដើម្បីធានាប្រសិទ្ធភាពកិច្ចព្រមព្រៀងនេះ ការពង្រឹងវិធានការទប់ស្កាត់ និងការបង្ក្រាបអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធនៅក្នុងដែនសមុទ្រដោយភាគីហត្ថលេខីនិមួយៗ គឺជាកត្តាដែលមិនអាចខ្វះបាន

ដោយមានការប្តេជ្ញាចិត្តក្នុងការលើកកំពស់កិច្ចសហការប្រចាំតំបន់ និងពង្រឹងប្រសិទ្ធភាពនៃកិច្ចសហការក្នុងកិច្ចការនេះ

ភាគីហត្ថលេខីបានព្រមព្រៀងដូចខាងក្រោមនេះ :

## ផ្នែកទី ១: សេចក្តីផ្តើម

## មាត្រា ១: និយមន័យ

១. ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ ពាក្យ "អំពើប្លន់នាវា" មានន័យថាអំពើណាមួយដូចខាងក្រោមនេះ :

ក- អំពើហិង្សា ឬឃុំឃាំងដោយខុសច្បាប់ ឬអំពើបំផ្លិចបំផ្លាញដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ដោយនាវិក ឬអ្នកដំណើរតាមនាវា ឬអាកាសយានឯកជនដោយមានគោលបំណង :

-ប្រឆាំងនិងនាវាផ្សេង ឬបុគ្គលផ្សេង ឬទ្រព្យសម្បត្តិនៅលើនាវាក្នុងសមុទ្រអន្តរជាតិ ។

-ប្រឆាំងនិងនាវា បុគ្គល ឬទ្រព្យសម្បត្តិក្នុងកន្លែងនៅក្រៅយុត្តាធិការនៃរដ្ឋ ។

ខ- រាល់អំពើនៃការចូលរួមដោយស្ម័គ្រចិត្តក្នុងការកំណើរការនាវា ឬ អាកាស-យាន ដោយបានដឹងពីអង្គហេតុដែលនាំអោយកើតជាអំពើប្លន់នាវា ឬអាកាសយាន ។

គ- អំពើនៃការញុះញង់ ឬការសំរួលអំពើល្មើសដោយចេតនាដែលកំណត់ក្នុងវាក្យខណ្ឌ (ក) ឬ (ខ) ។

២. ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ ពាក្យ "អំពើប្លន់ប្រដាប់អាវុធលើនាវា" មានន័យថាអំពើណាមួយដូចខាងក្រោមនេះ :

ក- អំពើហិង្សា ឬឃុំឃាំងដោយខុសច្បាប់ ឬអំពើបំផ្លិចបំផ្លាញដើម្បីប្រយោជន៍ផ្ទាល់ខ្លួន សំដៅប្រឆាំងនិងនាវា ឬបុគ្គល ឬទ្រព្យសម្បត្តិផ្ទុកលើនាវា នៅក្នុងកន្លែងដែលបទល្មើសនោះស្ថិតក្នុងយុត្តាធិការរបស់ភាគីហត្ថលេខី ។

ខ-រាល់អំពើនៃការចូលរួមដោយស្ម័គ្រចិត្តក្នុងការកំណើរការនាវា ឬដោយបានដឹងពីអង្គហេតុដែលនាំអោយកើតជាអំពើប្លន់ប្រដាប់អាវុធលើនាវា ។

គ- អំពើនៃការញុះញង់ ឬការសំរួលអំពើល្មើសដោយចេតនាដែលកំណត់ក្នុងវាក្យខណ្ឌ (ក) ឬ (ខ) ។

## មាត្រា ២: បទប្បញ្ញត្តិទូទៅ

១. អនុលោមតាមច្បាប់និងលិខិតបទដ្ឋានពាក់ព័ន្ធរបស់ខ្លួន និងអនុលោមតាមធនធាន ឬសមត្ថភាពដែលខ្លួនមាន ភាគីហត្ថលេខីត្រូវអនុវត្តកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងការទប់ស្កាត់ និងការបង្ក្រាបអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា អោយបានអស់ពីសមត្ថភាពរបស់ខ្លួន ។

២. គ្មានប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវមានអនុភាពលើសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីហត្ថលេខីតាមកិច្ចព្រមព្រៀងអន្តរជាតិ ដែលភាគីហត្ថលេខីជាភាគី ដែលរាប់បញ្ចូលទាំងច្បាប់សមុទ្ទ និងវិធានច្បាប់អន្តរជាតិផងដែរ ។

៣. គ្មានប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះ ត្រូវមានអនុភាពលើបុព្វសិទ្ធិនៃនាវាចំបាំង និងនាវារដ្ឋាភិបាលផ្សេងៗទៀត ដែលមិនធ្វើប្រតិបត្តិការក្នុងគោលបំណងពាណិជ្ជកម្មឡើយ ។

៤. គ្មានប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះ គ្មានអំពើ ឬសកម្មភាពណាមួយរបស់ភាគីហត្ថលេខីក្នុងកិច្ចព្រមព្រៀងនេះអាចប៉ះពាល់ដល់គោលជំហររបស់ភាគីហត្ថលេខីក្នុវិវាទណាមួយដែលទាក់ទិននិងបូរណភាពទឹកដី ឬបញ្ហាណាមួយដែលពាក់ព័ន្ធនឹងច្បាប់សមុទ្ទឡើយ ។

៥. គ្មានប្រការណាមួយក្នុងកិច្ចព្រមព្រៀងនេះ ដែលផ្តល់សិទ្ធិអោយភាគីហត្ថលេខីយកទឹកដីរបស់ភាគីហត្ថលេខីមួយផ្សេងទៀត ដើម្បីអនុវត្តយុត្តាធិការ និងបំពេញមុខងារដែលច្បាប់ជាតិរបស់រដ្ឋនោះ បានរក្សាសិទ្ធិទាំងស្រុងសំរាប់អាជ្ញាធររបស់ភាគីហត្ថលេខីផ្សេងនោះឡើយ ។

៦. ដើម្បីអនុវត្តកថាខណ្ឌទី ១ នៃមាត្រា ១ ភាគីហត្ថលេខីនីមួយៗ ត្រូវតែយកចិត្តទុកដាក់គោរពតាមបទប្បញ្ញត្តិទាក់ទិននៃច្បាប់សមុទ្ទ ដោយគ្មានការប៉ះពាល់ដល់សិទ្ធិរបស់ភាគីទីបីឡើយ ។

## មាត្រា ៣: ភាតព្វកិច្ចទូទៅ

១. អនុលោមតាមច្បាប់និងលិខិតបទដ្ឋានជាតិ និងអនុលោមតាមវិធានច្បាប់អន្តរជាតិជាធរមាន ភាគីហត្ថលេខីនិមួយៗត្រូវអនុវត្តរាល់កិច្ចប្រឹងប្រែងដើម្បីចាត់វិធានការមានប្រសិទ្ធភាព ចំពោះករណីដូចខាងក្រោមនេះ :

ក- ដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា ។

ខ- ដើម្បីចាប់ខ្លួនចោរប្លន់នាវា ឬជនដែលបានប្រព្រឹត្តអំពើប្លន់ប្រដាប់អាវុធលើនាវា ។

គ- ដើម្បីឃាត់នាវា ឬអាកាសយាន ដែលត្រូវបានប្រើប្រាស់សំរាប់ប្រព្រឹត្តបទប្លន់ ឬបទប្លន់ប្រដាប់អាវុធលើនាវា ដើម្បីឃាត់នាវាដែលត្រូវបានប្លន់ និងស្ថិតនៅក្រោមការកាន់កាប់របស់ចោរប្លន់ ឬ ជនដែលបានប្រព្រឹត្តអំពើប្លន់ប្រដាប់អាវុធលើនាវា និង ដើម្បីរឹបអូសទ្រព្យសម្បត្តិដែលផ្ទុកលើនាវានោះ និង

ឃ- ដើម្បីសង្គ្រោះនាវារងគ្រោះ និងជនរងគ្រោះពីអំពើប្លន់នាវា ឬអំពើប្លន់ប្រដាប់អាវុធលើនាវា ។

២. គ្មានប្រការណាមួយក្នុងមាត្រានេះ ដែលរាំងមិនអោយភាគីហត្ថលេខីចាត់វិធានការបន្ថែមលើវាក្យខណ្ឌ ក ដល់ ឃ ខាងលើ នៅក្នុងដែនដីរបស់ខ្លួនឡើយ ។

## ផ្នែកទី ២: មជ្ឈមណ្ឌលចែករំលែកព័ត៌មាន

### មាត្រា ៤: សមាសភាព

១. មជ្ឈមណ្ឌលចែករំលែកព័ត៌មាន ដែលហៅកាត់ថា “មជ្ឈមណ្ឌល” ត្រូវបានបង្កើតឡើង ដើម្បីលើកកំពស់កិច្ចសហប្រតិបត្តិការក្នុងចំណោមភាគីហត្ថលេខី ដើម្បីទប់ស្កាត់ និងបង្ក្រាបអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា ។

២. មជ្ឈមណ្ឌលនេះត្រូវស្ថិតនៅក្នុងប្រទេសសិង្ហបុរី ។

៣. មជ្ឈមណ្ឌលនេះត្រូវមានក្រុមប្រឹក្សាភិបាល និងលេខាធិការដ្ឋានមួយ ។

៤. ក្នុងសមាសភាពក្រុមប្រឹក្សាភិបាលត្រូវមានតំណាងមួយរូបរបស់ភាគីហត្ថលេខីនិមួយៗ ។ ក្រុមប្រឹក្សាត្រូវជួបប្រជុំយ៉ាងហោចម្តងក្នុងមួយឆ្នាំនៅក្នុងប្រទេសសិង្ហបុរី លើកលែងតែក្រុមប្រឹក្សាបានសំរេចផ្សេងពីនេះ ។

៥. ក្រុមប្រឹក្សាភិបាលមានអំណាចកំណត់គោលនយោបាយពាក់ព័ន្ធនិងគ្រប់កិច្ចការរបស់មជ្ឈមណ្ឌល ហើយត្រូវអនុម័តបទបញ្ជាផ្ទៃក្នុង រាប់បញ្ចូលទាំងវិធីសាស្ត្រជ្រើសតាំងប្រធានមជ្ឈមណ្ឌលផងដែរ ។

៦. ក្រុមប្រឹក្សាភិបាលធ្វើសេចក្តីសំរេចផ្អែកតាមគោលការណ៍មតិឯកភាពទូទៅ ។

៧. លេខាធិការដ្ឋានត្រូវដឹកនាំដោយនាយកប្រតិបត្តិមួយរូប ដោយមានបុគ្គលិកជំនួយការមួយចំនួន ។ នាយកប្រតិបត្តិត្រូវជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល ។

៨. នាយកប្រតិបត្តិត្រូវទទួលបន្ទុកកិច្ចការរដ្ឋបាល ប្រតិបត្តិការ និងបញ្ហាហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌល ដោយអនុលោមទៅតាមគោលនយោបាយដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល និងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ និងបញ្ហាដទៃទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ។

៩. នាយប្រតិបត្តិជាអ្នកតំណាងរបស់មជ្ឈមណ្ឌល ។ ដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិត្រូវតែចេញវិធាននិងបទបញ្ជាទាំងឡាយសំរាប់ដឹកនាំលេខាធិការដ្ឋាន ។

## មាត្រា ៥: កិច្ចព្រមព្រៀងអំពីទីស្នាក់ការកណ្តាល

១. មជ្ឈមណ្ឌល ដែលជាអង្គការអន្តរជាតិដែលមានសមាជិកជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងនេះ ត្រូវមានសមត្ថភាពពេញច្បាប់ អភ័យឯកសិទ្ធិ និងបុព្វសិទ្ធិនៅក្នុងរដ្ឋដែលមជ្ឈមណ្ឌលតាំងនៅ ដែលចាំបាច់សំរាប់ការបំពេញភារកិច្ចរបស់ខ្លួន ។

២. នៅក្នុងប្រទេសម្ចាស់ផ្ទះ នាយកប្រតិបត្តិ និងបុគ្គលិកនៃលេខាធិការដ្ឋានត្រូវប្រើអភ័យឯកសិទ្ធិ និងបុព្វសិទ្ធិ ក្នុងករណីចាំបាច់សំរាប់ការបពេញភារកិច្ចរបស់ខ្លួន ។

៣. មជ្ឈមណ្ឌលត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋម្ចាស់ផ្ទះចំពោះបញ្ហាទាំងឡាយដូចដែលបានចែងក្នុងកថាខណ្ឌទី ១ និង ២ នៃមាត្រានេះ ។

## មាត្រា ៦: កិច្ចការហិរញ្ញវត្ថុ

១. ការចំណាយទាំងឡាយ ដូចបានកំណត់ក្នុងថវិកាដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ត្រូវបានផ្តល់ដោយប្រភពដូចខាងក្រោមនេះ :

ក-ការផ្តល់ហិរញ្ញវត្ថុ និងការគាំទ្ររបស់រដ្ឋម្ចាស់ផ្ទះ

ខ-វិភាគទានដោយស្ម័គ្រចិត្តរបស់ភាគីហត្ថលេខី

គ-វិភាគទានដោយស្ម័គ្រចិត្តរបស់អង្គការអន្តរជាតិ និងស្ថាប័នអន្តជាតិផ្សេងៗ ស្របតាមលក្ខណៈវិនិច្ឆ័យដែលអនុម័តដោយក្រុមប្រឹក្សាភិបាល និង

ឃ-រាល់វិភាគទានដោយស្ម័គ្រចិត្តផ្សេងទៀត តាមការយល់ព្រមរបស់ក្រុមប្រឹក្សាភិបាល ។

២. បញ្ហាហិរញ្ញវត្ថុរបស់មជ្ឈមណ្ឌល នឹងត្រូវគ្រប់គ្រងដោយបទប្បញ្ញត្តិហិរញ្ញវត្ថុ ដែលត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល ។

៣. ត្រូវមានសវនកម្មប្រចាំឆ្នាំលើគណនីរបស់មជ្ឈមណ្ឌល ដែលត្រូវធ្វើឡើងដោយសវនករឯករាជ្យដែលតែងតាំងដោយក្រុមប្រឹក្សាភិបាល ។ របាយការណ៍សវនកម្មនឹងត្រូវបានដាក់ជូនក្រុមប្រឹក្សាភិបាល និងត្រូវកំណត់ជាឯកសារសាធារណៈស្របតាមបទបញ្ជាហិរញ្ញវត្ថុ ។

## មាត្រា ៧: ភារកិច្ចមុខងារ

មជ្ឈមណ្ឌលមានមុខងារដូចខាងក្រោមនេះ :

ក-ចាត់ចែង និងរៀបចំលំហូរព័ត៌មានដែលទាក់ទិននិងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវាអោយបានឆាប់រហ័សក្នុងចំណោមភាគីហត្ថលេខី ។

ខ-ប្រមូល ប្រៀបធៀប និងវិភាគព័ត៌មានដែលផ្តល់ដោយភាគីហត្ថលេខីដែលទាក់ទិននិងអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា រួមទាំងព័ត៌មានផ្សេងៗទៀតដែលទាក់ទិននិងឧក្រិដ្ឋជននិងក្រុមអង្គការចាត់តាំងឧក្រិដ្ឋជន ប្រសិនបើមាន ។

គ-រៀបចំស្ថិតិ និងរបាយការណ៍ផ្អែកតាមមូលដ្ឋានព័ត៌មានដែលប្រមូលបាន និងធ្វើការវិភាគស្របតាមកថាខណ្ឌ ខ រួចបញ្ជូនទៅអោយភាគីហត្ថលេខី ។

ឃ-ក្នុងករណីដែលអាចធ្វើទៅបាន ផ្តល់នូវការប្រកាសអាសន្នសមស្របជូនទៅភាគីហត្ថលេខី ប្រសិនបើមានមូលដ្ឋានសមស្របដែលគួរជឿបានថានឹងមានអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា ។

ង-ចែកផ្សាយសំណើទាំងឡាយដូចមានចែងក្នុងមាត្រា ១០ និងព័ត៌មានពាក់ព័ន្ធនិងវិធានការដែលបានអនុវត្តដូចមានចែងក្នុងមាត្រា ១១ ក្នុងចំណោមភាគីហត្ថលេខី ។

ច-រៀបចំស្ថិតិនិងរបាយការណ៍គ្មានចំណាត់ថ្នាក់ ផ្អែកតាមមូលដ្ឋានព័ត៌មានដែលប្រមូលបាន និងធ្វើការវិភាគស្របតាមកថាខណ្ឌ ខ រួចបញ្ជូនទៅអោយសហគមន៍នាវាចរណ៍ និងអង្គការអន្តរជាតិទទួលបន្ទុកកិច្ចការសមុទ្ទ និង

ឆ-អនុវត្តមុខងារផ្សេងៗទៀត ដូចដែលបានឯកភាពដោយក្រុមប្រឹក្សាភិបាលក្នុងទស្សនៈទប់ស្កាត់ និងបង្ក្រាបអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា ។

## មាត្រា ៨: ប្រតិបត្តិការ

១. ប្រតិបត្តិការប្រចាំថ្ងៃរបស់មជ្ឈមណ្ឌលនឹងត្រូវអនុវត្តដោយលេខាធិការដ្ឋាន ។

២. ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មជ្ឈមណ្ឌលត្រូវតែគោរពនិងរក្សាការសម្ងាត់នៃព័ត៌មានដែលផ្តល់ដោយភាគីហត្ថលេខីណាមួយ ហើយមិនត្រូវបញ្ចេញឬចែកផ្សាយព័ត៌មាននោះឡើយ លើកលែងតែមានការយល់ព្រមជាមុនពីភាគីហត្ថលេខីនោះ ។

៣. មជ្ឈមណ្ឌលត្រូវធ្វើប្រតិបត្តិការក្នុងលក្ខណៈដែលមានប្រសិទ្ធភាព និងមានតម្លាភាព ស្របតាមគោលនយោបាយដែលអនុម័តដោយក្រុមប្រឹក្សាភិបាល ហើយត្រូវជៀសវាងការងារដែលត្រួតគ្នារវាងភាគីហត្ថលេខីនានា ។

## ផ្នែកទី ៣៖ កិច្ចសហការតាមរយៈមជ្ឈមណ្ឌលចែករំលែកព័ត៌មាន

## មាត្រា ៩៖ ការចែករំលែកព័ត៌មាន

១. ភាគីហត្ថលេខីនិមួយៗត្រូវតែបង្កើតចំណុចកណ្តាលដែលទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយមជ្ឈមណ្ឌល ហើយត្រូវប្រកាសបង្កើតចំណុចកណ្តាលនេះ នៅពេលដែលខ្លួនចុះហត្ថលេខា ឬបានតម្កល់លិខិតុបករណ៍នៃការជូនដំណឹង ដូចមានចែងក្នុងមាត្រា ១៨ ។

២. នៅពេលមានសំណើពីមជ្ឈមណ្ឌល ភាគីហត្ថលេខីនិមួយៗត្រូវតែរក្សាការសម្ងាត់នៃព័ត៌មានដែលបានបញ្ជូនមកពីមជ្ឈមណ្ឌល ។

៣. ភាគីហត្ថលេខីនិមួយៗ ត្រូវតែធានាអោយទំនាក់ទំនងព័ត៌មានមានភាពរលូន និងមានប្រសិទ្ធភាពរវាងចំណុចកណ្តាលដែលបានតែងតាំង និងអាជ្ញាធរជាតិមានសមត្ថកិច្ចផ្សេងទៀត ជាអាទិ៍មានមជ្ឈមណ្ឌលសំរបសំរួលការសង្គ្រោះ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលដែលមានការពាក់ព័ន្ធជាដើម ។

៤. ភាគីហត្ថលេខីនិមួយៗ ត្រូវតែអនុវត្តរាល់កិច្ចប្រឹងប្រែងដើម្បីតម្រូវអោយនាវាម្ចាស់នាវា ឬអ្នកដំណើរការនាវា ផ្តល់ដំណឹងភ្លាមៗមកអាជ្ញាធរជាតិដែលពាក់ព័ន្ធ រាប់បញ្ចូលទាំងចំណុចកណ្តាល និងមជ្ឈមណ្ឌលអំពីឧបត្តិហេតុនៃអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា កាលណាអាចធ្វើទៅបាន ។

៥. រាល់ភាគីហត្ថលេខីដែលបានទទួល ឬទទួលបានពត៌មានអំពីការគំរាមកំហែងជាក់ស្តែង ឬពីឧបត្តិហេតុនៃអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា ត្រូវតែផ្តល់ព័ត៌មានដែលទាក់ទិនទៅមជ្ឈមណ្ឌល តាមរយៈចំណុចកណ្តាលរបស់ខ្លួន ។

៦. ក្នុងករណីដែល ភាគីហត្ថលេខីដែលបានទទួលការប្រកាសភាពអាសន្នពីមជ្ឈមណ្ឌល អំពីការគំរាមកំហែងជាក់ស្តែង ឬពីឧបត្តិហេតុនៃអំពើប្លន់នាវា និង

អំពើប្លន់ប្រដាប់អាវុធលើនាវា អនុលោមតាមកថាខណ្ឌ ឃ នៃមាត្រា ៧ ភាគីហត្ថលេខីនេះ ត្រូវតែផ្តល់ព័ត៌មានអំពីការប្រកាសភាពអាសន្ននេះភ្លាមៗ ដល់នាវាទាំងឡាយដែលស្ថិតក្នុងតំបន់មានការគំរាមកំហែងជាក់ស្តែងនោះ ។

## មាត្រា ១០: សំណើសុំកិច្ចសហប្រតិបត្តិការ

១. ភាគីហត្ថលេខីអាចស្នើទៅភាគីហត្ថលេខីផ្សេងទៀត តាមរយៈមជ្ឈមណ្ឌល ឬដោយផ្ទាល់ ដើម្បីសុំអោយមានកិច្ចសហប្រតិបត្តិការក្នុងការអង្កេតតាមដានលើបុគ្គល នាវា ឬអាកាសយានដូចខាងក្រោមនេះ :

ក-ចោរប្លន់នាវា

ខ-បុគ្គលដែលបានប្រព្រឹត្តបទប្លន់ប្រដាប់អាវុធលើនាវា

គ-នាវា ឬអាកាសយានដែលត្រូវបានប្រើដើម្បីប្រព្រឹត្តបទប្លន់នាវានិងបទប្លន់ប្រដាប់អាវុធលើនាវា និងនាវាដែលបានកាន់កាប់ និងស្ថិតក្រោមការគ្រប់គ្រងរបស់ចោរប្លន់នាវា ឬ បុគ្គលដែលបានប្រព្រឹត្តបទប្លន់ប្រដាប់អាវុធលើនាវា ឬ

ឃ-នាវារងគ្រោះ និងជនរងគ្រោះពីអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា ។

២. ភាគីហត្ថលេខីអាចស្នើសុំអោយភាគីហត្ថលេខីណាមួយផ្សេងទៀត តាមរយៈមជ្ឈមណ្ឌល ឬដោយផ្ទាល់ ដើម្បីសុំអោយចាត់វិធានការសមស្រប ដូចជាការចាប់ ឬការឃាត់ខ្លួនបុគ្គល ឬនាវាដូចមានចែងក្នុងវាក្យខណ្ឌ ក ខ ឬ គ នៃកថាខណ្ឌទី ១ ក្នុងមាត្រានេះ ក្នុងវិសាលភាពដែលច្បាប់និងលិខិតបដ្ឋានជាតិរបស់ខ្លួនបានអនុញ្ញាត និងតាមវិធានច្បាប់អន្តរជាតិជាធរមាន ។

៣. ភាគីហត្ថលេខីអាចស្នើសុំអោយភាគីហត្ថលេខីណាមួយផ្សេងទៀត តាមរយៈមជ្ឈមណ្ឌល ឬដោយផ្ទាល់ ដើម្បីសុំអោយចាត់វិធានការមានប្រសិទ្ធភាព

ដើម្បីសង្គ្រោះនាវារងគ្រោះ និងជនរងគ្រោះពីអំពើប្លន់នាវា និងអំពើប្លន់ប្រដាប់អាវុធលើនាវា ។

៤. ភាគីហត្ថលេខី ដែលបានធ្វើសំណើសុំកិច្ចសហប្រតិបត្តិការដោយផ្ទាល់ អនុលោមតាមកថាខណ្ឌទី ១ ២ និង ៣ នៃមាត្រានេះ ត្រូវតែជូនដំណឹងពីសំណើនោះមកមជ្ឈមណ្ឌលអោយបានឆាប់បំផុត ។

៥. រាល់សំណើរបស់ភាគីហត្ថលេខីដែលស្នើសុំកិច្ចសហប្រតិបត្តិការដែលទាក់ទិន និងបិត្យាប័ន ឬជំនួយខាងច្បាប់ទៅវិញទៅមកក្នុងករណីព្រហ្មទណ្ឌ ត្រូវតែធ្វើដោយផ្ទាល់ទៅភាគីម្ខាងទៀតនោះ ។

## មាត្រា ១១: កិច្ចសហប្រតិបត្តិការតាមសំណើភាគីហត្ថលេខី

១. ភាគីហត្ថលេខីដែលបានទទួលសំណើស្របតាមមាត្រា ១០ និងអនុលោមតាមកថាខណ្ឌទី ១ នៃមាត្រា ២ ត្រូវតែអនុវត្តរាល់កិច្ចប្រឹងប្រែង ដើម្បីចាត់វិធានការមានប្រសិទ្ធភាព និងជាក់ស្តែងដើម្បីអនុវត្តសំណើនោះ ។

២. ភាគីហត្ថលេខីដែលបានទទួលសំណើស្របតាមមាត្រា ១០ អាចស្វែងរកព័ត៌មានបន្ថែមពីភាគីដែលបានស្នើសុំ ដើម្បីអនុវត្តសំណើនោះ ។

៣. ភាគីហត្ថលេខីដែលបានចាត់វិធានការដូចបានចែងក្នុងកាថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវជូនដំណឹងអំពីព័ត៌មាននៃការចាត់វិធានការទៅមជ្ឈមណ្ឌលអោយបានឆាប់បំផុត ។

## ផ្នែកទី ៤: កិច្ចសហប្រតិបត្តិការ

## មាត្រា ១២: អំពីបិត្យាប័ន

អនុលោមតាមច្បាប់និងលិខិតបទដ្ឋានជាតិរបស់ខ្លួន ភាគីហត្ថលេខីត្រូវតែអនុវត្តកិច្ចប្រឹងប្រែងដើម្បីធ្វើបិត្យាប័នចោរប្លន់នាវា ឬបុគ្គលដែលបានប្រព្រឹត្តអំពើប្លន់ប្រដាប់អាវុធលើនាវា ហើយដែលកំពុងស្ថិតនៅក្នុងទឹកដីរបស់ខ្លួនទៅអោយភាគីហត្ថលេខីដែលមានយុត្តាធិការលើជនទាំងនោះ តាមសំណើរបស់ភាគីហត្ថលេខី ។

## មាត្រា ១៣: ជំនួយកិច្ចការច្បាប់នៅវិញនៅមក

អនុលោមតាមច្បាប់និងលិខិតបទដ្ឋានជាតិរបស់ខ្លួន ភាគីហត្ថលេខីត្រូវតែអនុវត្តកិច្ចប្រឹងប្រែងដើម្បីផ្តល់ជំនួយផ្នែកច្បាប់ក្នុងករណីព្រហ្មទណ្ឌ ជាអាទិ៍មានការដាក់ជូនភស្តុតាងទាក់ទិននិងអំពើប្លន់នាវា ឬអំពើប្លន់ប្រដាប់អាវុធលើនាវា តាមសំណើរបស់ភាគីហត្ថលេខីមួយផ្សេងទៀត ។

## មាត្រា ១៤: ការកសាងសមត្ថភាព

១. ដើម្បីពង្រឹងសមត្ថភាពរបស់ភាគីហត្ថលេខីក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើប្លន់នាវា ឬអំពើប្លន់ប្រដាប់អាវុធលើនាវា ភាគីហត្ថលេខីត្រូវអនុវត្តកិច្ចប្រឹងប្រែងដើម្បីសហការអោយបានអស់ពីសមត្ថភាពដែលអាចធ្វើទៅបាន ជាមួយភាគីហត្ថលេខីមួយផ្សេងទៀតដែលបានស្នើសុំកិច្ចប្រតិបត្តិការ ឬជំនួយ ។

២. មជ្ឈមណ្ឌល ត្រូវអនុវត្តកិច្ចប្រឹងប្រែងដើម្បីសហការអោយបានអស់ពីសមត្ថភាពដែលអាចធ្វើទៅបាន ដើម្បីផ្តល់ជំនួយខាងការកសាងសមត្ថភាព ។

៣. កិច្ចសហប្រតិបត្តិការកសាងសមត្ថភាព អាចស្ថិតក្នុងរូបភាពជំនួយបច្ចេកទេស ដូចជាកម្មវិធីអប់រំ និងបណ្តុះបណ្តាល ដើម្បីចែករំលែកព័ត៌មាននិងទម្លាប់-អនុវត្តប្រសើរបំផុត ។

## មាត្រា ១៥: កិច្ចព្រមព្រៀងសហប្រតិបត្តិការ

កិច្ចព្រមព្រៀងសហប្រតិបត្តិការ ដូចជាការអនុវត្តការងាររួមគ្នា ឬកិច្ចសហ-ប្រតិបត្តិការក្នុងរូបភាពផ្សេងទៀត ដែលសមស្រប អាចត្រូវបានព្រមព្រៀងរវាងភាគីហត្ថលេខី ។

## មាត្រា ១៦: វិធានការការពារនាវា

ភាគីហត្ថលេខីនិមួយៗ ត្រូវលើកទឹកចិត្តអោយនាវា ម្ចាស់នាវា ឬអ្នកដំណើរការនាវា ចាត់វិធានការការពារប្រឆាំងនិងអំពើប្លន់នាវា ឬអំពើប្លន់ប្រដាប់អាវុធលើនាវា ដោយគោរពទៅតាមស្តង់ដារ និងទម្លាប់អនុវត្តអន្តរជាតិដែលទាក់ទិនជាពិសេស អនុសាសន៍ទាំងឡាយដែលអនុម័តដោយអង្គការអន្តរជាតិទទួលបន្ទុកកិច្ចការសមុទ្ទ ។

## ផ្នែកទី ៥: បទប្បញ្ញត្តិអវសាន

## មាត្រា ១៧: ការដោះស្រាយវិវាទ

វិវាទទាំងឡាយដែលកើតចេញពីការបកស្រាយ ឬអនុវត្តកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងវិវាទដែលទាក់ទិននិងការទទួលខុសត្រូវចំពោះការខាតបង់ ឬការអន្តរាយដែលបានបង្ករឡើងដោយសំណើរបស់ភាគីហត្ថលេខី ដែលធ្វើឡើងតាមកថាខណ្ឌទី ២ នៃមាត្រា ១០ ឬបង្ករឡើងដោយសារវិធានការដែលបានធ្វើឡើងតាមកថាខណ្ឌទី ១ នៃមាត្រា ១១ ត្រូវដោះស្រាយតាមគោលការណ៍ភាតរភាពរវាង

ភាគីហត្ថលេខី តាមរយៈការចរចារដោយអនុលោមទៅតាមវិធានច្បាប់អន្តរជាតិជាធរមាន ។

## មាត្រា ១៨: ការចុះហត្ថលេខានិងការចូលជាធរមាន

១. កិច្ចព្រមព្រៀងនេះត្រូវទុកចំហអោយចុះហត្ថលេខា នៅការិយាល័យតម្កល់ដូចមានចែងនៅក្នុងកថាខណ្ឌទី ២ ខាងក្រោម ដោយសាធារណរដ្ឋប្រជាមានិតុបង់ក្លាដែស ប្រ៊ុយណេដារូស្សាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតុចិន សាធារណរដ្ឋឥណ្ឌា សាធារណរដ្ឋឥណ្ឌូនេស៊ី ប្រទេសជប៉ុន សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋប្រជាមានិតុប្រជាធិបតេយ្យឡាវ ប្រទេសម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី សាធារណរដ្ឋប្រជាធិបតេយ្យសង្គមនិយមស្រីលង្កា ព្រះរាជាណាចក្រថៃឡង់ដ៍ សាធារណរដ្ឋសង្គមនិយមវៀតណាម ។

២. រដ្ឋាភិបាលសិង្ហបុរីជាការិយាល័យតម្កល់កិច្ចព្រមព្រៀងនេះ ។

៣. កិច្ចព្រមព្រៀងនេះ ត្រូវចូលជាធរមានក្នុងរយៈពេលកៅសិប (៩០)ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទ ដែលលិខិតុបករណ៍ជូនដំណឹងទី ១០ របស់រដ្ឋដែលមានរាយនាមក្នុងកថាខណ្ឌទី ១ ដែលចង្អុលបង្ហាញពីការបំពេញលក្ខខណ្ឌតម្រូវក្នុងស្រុកចប់សព្វគ្រប់ ត្រូវបានដាក់ជូនទៅការិយាល័យតម្កល់ ។ បន្ទាប់មកកិច្ចព្រមព្រៀងនេះ នឹងចូលជាធរមានចំពោះរដ្ឋណាមួយផ្សេងទៀតដែលបានរាយនាមក្នុងកថាខណ្ឌទី ១ ខាងលើ ក្នុងរយៈពេលសាមសិប(៣០) ថ្ងៃ បន្ទាប់ពីបានតម្កល់លិខិតុបករណ៍ជូនដំណឹងនៅការិយាល័យតម្កល់ ។

៤. ការិយាល័យតម្កល់ ត្រូវជូនដំណឹងដល់រដ្ឋទាំងអស់ដូចបានរាយនាមក្នុងកថាខណ្ឌទី ១ អំពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ អនុលោមតាមកថាខណ្ឌទី ៣ នៃមាត្រានេះ ។

៥. ក្រោយពីកិច្ចព្រមព្រៀងនេះបានចូលជាធរមាន នឹងមានការបើកចំហអោយរដ្ឋផ្សេងទៀតដែលមិនបានរាយនាមក្នុងកថាខណ្ឌទី ១ សុំចូលជាសមាជិក ។ រដ្ឋណាមួយដែលមានបំណងចង់ចូលជាសមាជិកនៃកិច្ចព្រមព្រៀងនេះ អាចជូនដំណឹងទៅការិយាល័យតម្កល់ ដែលការិយាល័យនេះនឹងបញ្ជូនលិខិតបញ្ជាក់ការទទួលលិខិតជូនដំណឹងទៅភាគីហត្ថលេខីទាំងអស់ ។ ក្នុងករណីគ្មានការជំទាស់ពីភាគីហត្ថលេខី ក្នុងរយៈពេលកៅសិប(៩០)ថ្ងៃបន្ទាប់ពីការិយាល័យតម្កល់បានទទួលលិខិតជូនដំណឹងនេះ រដ្ឋនោះអាចដាក់ពាក្យសុំចូលជាសមាជិកនៅការិយាល័យតម្កល់ ហើយក្លាយទៅជាភាគីនៃកិច្ចព្រមព្រៀងនេះក្នុងរយៈពេលហុកសិប (៦០)ថ្ងៃបន្ទាប់ពីការតម្កល់ពាក្យសុំចូលជាសមាជិកនេះ ។

## មាត្រា ១៩: វិសោធនកម្ម

១. បន្ទាប់ពីការចូលជាធរមាន ភាគីហត្ថលេខីអាចស្នើសុំធ្វើវិសោធនកម្មកិច្ចព្រមព្រៀងនេះ នៅពេលណាក៏បាន ។ វិសោធនកម្មនេះនឹងត្រូវអនុម័តដោយដោយមានការឯកភាពពីភាគីហត្ថលេខីទាំងអស់ ។

២. រាល់វិសោធនកម្មនឹងចូលជាធរមានក្នុងរយៈពេលកៅសិប (៩០)ថ្ងៃបន្ទាប់ពីមានការទទួលយល់ព្រមពីភាគីហត្ថលេខីទាំងអស់ ។ លិខិតបញ្ជាក់ការទទួលយល់ព្រមត្រូវតម្កល់នៅការិយាល័យតម្កល់ ដែលការិយាល័យនេះនឹងជូនដំណឹងពីការតម្កល់នេះទៅភាគីហត្ថលេខីទាំងអស់ ។

## មាត្រា ២០: ការដកសមាជិកភាព

១. បន្ទាប់ពីការចូលជាធរមាន ភាគីហត្ថលេខីអាចស្នើសុំដកខ្លួនចេញពីកិច្ចព្រមព្រៀងនេះ នៅពេលណាក៏បាន ។

២. ភាគីដែលដកខ្លួនចេញត្រូវតម្កល់លិខិតសុំដកសមាជិកភាព នៅការិយាល័យតម្កល់ ។

៣. ការសុំដកសមាជិកភាពនឹងចូលជាធរមាន ក្នុងរយៈពេលមួយរយប៉ែតសិប (១៨០)ថ្ងៃ បន្ទាប់ពីការិយាល័យតម្កល់បានទទួលលិខិតសុំដកសមាជិកភាពនោះ ។

៤. ការិយាល័យតម្កល់ ត្រូវជូនដំណឹងពីគ្រប់ការដកសមាជិកភាព ទៅភាគី-ហត្ថលេខីផ្សេងទៀតទាំងអស់អោយបានឆាប់បំផុត ។

## មាត្រា ២១: អត្ថបទផ្លូវការ

អត្ថបទជាផ្លូវការនៃកិច្ចព្រមព្រៀងនេះ គឺអត្ថបទជាភាសាអង់គ្លេស ។

## មាត្រា ២២: ការចុះបញ្ជី

កិច្ចព្រមព្រៀងនេះ នឹងត្រូវចុះបញ្ជីដោយការិយាល័យតម្កល់ អនុលោមតាម មាត្រា ១០២ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

**ដើម្បីជាសក្ខីភាពនៃកិច្ចព្រមព្រៀងនេះ** ហត្ថលេខីដូចរាយនាមខាងក្រោមដែលបាន ទទួលអំណាចចុះហត្ថលេខាត្រឹមត្រូវពីរដ្ឋាភិបាលខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

| | |
|---|---|
| សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ | ប្រទេសជប៉ុន |
| Done Somvorachit<br>អគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព | Ichiro Aisawa<br>អនុទេសរដ្ឋមន្ត្រីការបរទេស |
| សាធារណរដ្ឋសិង្ហបុរី | ព្រះរាជាណាចក្រកម្ពុជា |
| Raymond Lim<br>រដ្ឋមន្ត្រីស្ដីទីក្រសួងការបរទេស | Kem Mongkol<br>អគ្គរាជទូតវិសាមញ្ញនិងពេញសមត្ថភាព |

MINISTRY OF FOREIGN AFFAIRS
SINGAPORE

**BY DESPATCH**

3 May 2005

Mr Sieng Bun Vuth
Minister Counsellor
Royal Embassy of Cambodia

**CERTIFIED TRUE COPY OF THE RECAAP AGREEMENT**

1 The signing of the ReCAAP Agreement on 28 April 2005 was a success. I would like to hereby extend my appreciation for the Embassy's assistance.

2 Please find enclosed a certified true copy of the ReCAAP Agreement for the Embassy's reference. It would be appreciated if the Embassy could forward the Ministry of Foreign Affairs the instrument of ratification once Cambodia's domestic requirements have been completed.

3 Thank you.

ETHAN CHUA
for PERMANENT SECRETARY

enc.

## Regional Cooperation Agreement on Combating Piracy and Armed Robbery against Ships in Asia

The Contracting Parties to this Agreement,

Concerned about the increasing number of incidents of piracy and armed robbery against ships in Asia,

Mindful of the complex nature of the problem of piracy and armed robbery against ships,

Recognizing the importance of safety of ships, including their crew, exercising the right of navigation provided for in the United Nations Convention on the Law of the Sea of 10 December 1982, hereinafter referred to as "the UNCLOS",

Reaffirming the duty of States to cooperate in the prevention and suppression of piracy under the UNCLOS,

Recalling "Tokyo Appeal" of March 2000, "Asia Anti-Piracy Challenges 2000" of April 2000 and "Tokyo Model Action Plan" of April 2000,

Noting the relevant resolutions adopted by the United Nations General Assembly and the relevant resolutions and recommendations adopted by the International Maritime Organization,

Conscious of the importance of international cooperation as well as the urgent need for greater regional cooperation and coordination of all States affected within Asia, to prevent and suppress piracy and armed robbery against ships effectively,

Convinced that information sharing and capacity building among the Contracting Parties will significantly contribute towards the prevention and suppression of piracy and armed robbery against ships in Asia,

Affirming that, to ensure greater effectiveness of this Agreement, it is indispensable for each Contracting Party to strengthen its measures aimed at preventing and suppressing piracy and armed robbery against ships,

Determined to promote further regional cooperation and to enhance the effectiveness of such cooperation,

Have agreed as follows:

Certified ~~true signature/ true document~~/true copy

Usha Devi Kannan

3 MAY 2005

## Part I Introduction

### Article 1
### Definitions

1. For the purposes of this Agreement, "piracy" means any of the following acts:

(a) any illegal act of violence or detention, or any act of depredation, committed for private ends by the crew or the passengers of a private ship or a private aircraft, and directed:

(i) on the high seas, against another ship, or against persons or property on board such ship;

(ii) against a ship, persons or property in a place outside the jurisdiction of any State;

(b) any act of voluntary participation in the operation of a ship or of an aircraft with knowledge of facts making it a pirate ship or aircraft;

(c) any act of inciting or of intentionally facilitating an act described in subparagraph (a) or (b).

2. For the purposes of this Agreement, "armed robbery against ships" means any of the following acts:

(a) any illegal act of violence or detention, or any act of depredation, committed for private ends and directed against a ship, or against persons or property on board such ship, in a place within a Contracting Party's jurisdiction over such offences;

(b) any act of voluntary participation in the operation of a ship with knowledge of facts making it a ship for armed robbery against ships;

(c) any act of inciting or of intentionally facilitating an act described in subparagraph (a) or (b).

## Article 2
## General Provisions

1. The Contracting Parties shall, in accordance with their respective national laws and regulations and subject to their available resources or capabilities, implement this Agreement, including preventing and suppressing piracy and armed robbery against ships, to the fullest extent possible.

2. Nothing in this Agreement shall affect the rights and obligations of any Contracting Party under the international agreements to which that Contracting Party is party, including the UNCLOS, and the relevant rules of international law.

3. Nothing in this Agreement shall affect the immunities of warships and other government ships operated for non-commercial purposes.

4. Nothing in this Agreement, nor any act or activity carried out under this Agreement shall prejudice the position of any Contracting Party with regard to any dispute concerning territorial sovereignty or any issues related to the law of the sea.

5. Nothing in this Agreement entitles a Contracting Party to undertake in the territory of another Contracting Party the exercise of jurisdiction and performance of functions which are exclusively reserved for the authorities of that other Contracting Party by its national law.

6. In applying paragraph 1 of Article 1, each Contracting Party shall give due regard to the relevant provisions of the UNCLOS without prejudice to the rights of the third Parties.

## Article 3
## General Obligations

1. Each Contracting Party shall, in accordance with its national laws and regulations and applicable rules of international law, make every effort to take effective measures in respect of the following:

   (a) to prevent and suppress piracy and armed robbery against ships;
   (b) to arrest pirates or persons who have committed armed robbery against ships;
   (c) to seize ships or aircraft used for committing piracy or armed robbery against ships, to seize ships taken by and under the control of pirates or persons who have committed armed robbery against ships, and to seize the property on board such ships; and
   (d) to rescue victim ships and victims of piracy or armed robbery against ships.

2. Nothing in this Article shall prevent each Contracting Party from taking additional measures in respect of subparagraphs (a) to (d) above in its land territory

## Part II Information Sharing Center

### Article 4
### Composition

1. An Information Sharing Center, hereinafter referred to as "the Center", is hereby established to promote close cooperation among the Contracting Parties in preventing and suppressing piracy and armed robbery against ships.

2. The Center shall be located in Singapore

3. The Center shall be composed of the Governing Council and the Secretariat.

4. The Governing Council shall be composed of one representative from each Contracting Party. The Governing Council shall meet at least once every year in Singapore, unless otherwise decided by the Governing Council.

5. The Governing Council shall make policies concerning all the matters of the Center and shall adopt its own rules of procedure, including the method of selecting its Chairperson.

6. The Governing Council shall take its decisions by consensus.

7. The Secretariat shall be headed by the Executive Director who shall be assisted by the staff. The Executive Director shall be chosen by the Governing Council.

8. The Executive Director shall be responsible for the administrative, operational and financial matters of the Center in accordance with the policies as determined by the Governing Council and the provisions of this Agreement, and for such other matters as determined by the Governing Council.

9. The Executive Director shall represent the Center. The Executive Director shall, with the approval of the Governing Council, make rules and regulations of the Secretariat.

### Article 5
### Headquarters Agreement

1. The Center, as an international organization whose members are the Contracting Parties to this Agreement, shall enjoy such legal capacity, privileges and immunities in the Host State of the Center as are necessary for the fulfillment of its functions.

2. The Executive Director and the staff of the Secretariat shall be accorded, in the Host State, such privileges and immunities as are necessary for the fulfillment of their functions.

3. The Center shall enter into an agreement with the Host State on matters including those specified in paragraphs 1 and 2 of this Article.

### Article 6
### Financing

1. The expenses of the Center, as provided for in the budget decided by the Governing Council, shall be provided by the following sources:

   (a) Host State financing and support;
   (b) Voluntary contributions from the Contracting Parties;
   (c) Voluntary contributions from international organizations and other entities, in accordance with relevant criteria adopted by the Governing Council; and
   (d) Any other voluntary contributions as may be agreed upon by the Governing Council.

2. Financial matters of the Center shall be governed by a Financial Regulation to be adopted by the Governing Council.

3. There shall be an annual audit of the accounts of the Center by an independent auditor appointed by the Governing Council. The audit report shall be submitted to the Governing Council and shall be made public, in accordance with the Financial Regulation.

## Article 7
## Functions

The functions of the Center shall be:

(a) to manage and maintain the expeditious flow of information relating to incidents of piracy and armed robbery against ships among the Contracting Parties;

(b) to collect, collate and analyze the information transmitted by the Contracting Parties concerning piracy and armed robbery against ships, including other relevant information, if any, relating to individuals and transnational organized criminal groups committing acts of piracy and armed robbery against ships;

(c) to prepare statistics and reports on the basis of the information gathered and analyzed under subparagraph (b), and to disseminate them to the Contracting Parties;

(d) to provide an appropriate alert, whenever possible, to the Contracting Parties if there is a reasonable ground to believe that a threat of incidents of piracy or armed robbery against ships is imminent;

(e) to circulate requests referred to in Article 10 and relevant information on the measures taken referred to in Article 11 among the Contracting Parties;

(f) to prepare non-classified statistics and reports based on information gathered and analyzed under subparagraph (b) and to disseminate them to the shipping community and the International Maritime Organization; and

(g) to perform such other functions as may be agreed upon by the Governing Council with a view to preventing and suppressing piracy and armed robbery against ships.

## Article 8
## Operation

1. The daily operation of the Center shall be undertaken by the Secretariat.

2. In carrying out its functions, the Center shall respect the confidentiality of information provided by any Contracting Party, and shall not release or disseminate such information unless the consent of that Contracting Party is given in advance.

3. The Center shall be operated in an effective and transparent manner, in accordance with the policies made by the Governing Council, and shall avoid duplication of existing activities between the Contracting Parties.

## Part III Cooperation through the Information Sharing Center

### Article 9
### Information Sharing

1. Each Contracting Party shall designate a focal point responsible for its communication with the Center, and shall declare its designation of such focal point at the time of its signature or its deposit of an instrument of notification provided for in Article 18.

2. Each Contracting Party shall, upon the request of the Center, respect the confidentiality of information transmitted from the Center.

3. Each Contracting Party shall ensure the smooth and effective communication between its designated focal point, and other competent national authorities including rescue coordination centers, as well as relevant non-governmental organizations.

4. Each Contracting Party shall make every effort to require its ships, ship owners, or ship operators to promptly notify relevant national authorities including focal points, and the Center when appropriate, of incidents of piracy or armed robbery against ships.

5. Any Contracting Party which has received or obtained information about an imminent threat of, or an incident of, piracy or armed robbery against ships shall promptly notify relevant information to the Center through its designated focal point.

6. In the event that a Contracting Party receives an alert from the Center as to an imminent threat of piracy or armed robbery against ships pursuant to subparagraph (d) of Article 7, that Contracting Party shall promptly disseminate the alert to ships within the area of such an imminent threat.

## Article 10
## Request for Cooperation

1. A Contracting Party may request any other Contracting Party, through the Center or directly, to cooperate in detecting any of the following persons, ships, or aircraft:

   (a) pirates;
   (b) persons who have committed armed robbery against ships;
   (c) ships or aircraft used for committing piracy or armed robbery against ships, and ships taken by and under the control of pirates or persons who have committed armed robbery against ships; or
   (d) victim ships and victims of piracy or armed robbery against ships.

2. A Contracting Party may request any other Contracting Party, through the Center or directly, to take appropriate measures, including arrest or seizure, against any of the persons or ships mentioned in subparagraph (a), (b), or (c) of paragraph 1 of this Article, within the limits permitted by its national laws and regulations and applicable rules of international law.

3. A Contracting Party may also request any other Contracting Party, through the Center or directly, to take effective measures to rescue the victim ships and the victims of piracy or armed robbery against ships.

4. The Contracting Party which has made a direct request for cooperation pursuant to paragraphs 1, 2 and 3 of this Article shall promptly notify the Center of such request.

5. Any request by a Contracting Party for cooperation involving extradition or mutual legal assistance in criminal matters shall be made directly to any other Contracting Party.

## Article 11
## Cooperation by the Requested Contracting Party

1. A Contracting Party, which has received a request pursuant to Article 10, shall, subject to paragraph 1 of Article 2, make every effort to take effective and practical measures for implementing such request.

2. A Contracting Party, which has received a request pursuant to Article 10, may seek additional information from the requesting Contracting Party for the implementation of such request.

3. A Contracting Party, which has taken measures referred to in paragraph 1 of this Article, shall promptly notify the Center of the relevant information on the measures taken.

# Part IV Cooperation

## Article 12
## Extradition

A Contracting Party shall, subject to its national laws and regulations, endeavor to extradite pirates or persons who have committed armed robbery against ships, and who are present in its territory, to the other Contracting Party which has jurisdiction over them, at the request of that Contracting Party.

## Article 13
## Mutual Legal Assistance

A Contracting Party shall, subject to its national laws and regulations, endeavor to render mutual legal assistance in criminal matters, including the submission of evidence related to piracy and armed robbery against ships, at the request of another Contracting Party.

## Article 14
### Capacity Building

1. For the purpose of enhancing the capacity of the Contracting Parties to prevent and suppress piracy and armed robbery against ships, each Contracting Party shall endeavor to cooperate to the fullest possible extent with other Contracting Parties which request cooperation or assistance.

2. The Center shall endeavor to cooperate to the fullest possible extent in providing capacity building assistance.

3. Such capacity building cooperation may include technical assistance such as educational and training programs to share experiences and best practices.

## Article 15
### Cooperative Arrangements

Cooperative arrangements such as joint exercises or other forms of cooperation, as appropriate, may be agreed upon among the Contracting Parties concerned.

## Article 16
### Protection Measures for Ships

Each Contracting Party shall encourage ships, ship owners, or ship operators, where appropriate, to take protective measures against piracy and armed robbery against ships, taking into account the relevant international standards and practices, in particular, recommendations adopted by the International Maritime Organization.

# Part V Final Provisions

## Article 17
### Settlement of Disputes

Disputes arising out of the interpretation or application of this Agreement, including those relating to liability for any loss or damage caused by the request made under paragraph 2 of Article 10 or any measure taken under paragraph 1 of Article 11, shall be settled amicably by the Contracting Parties concerned through negotiations in accordance with applicable rules of international law.

## Article 18
## Signature and Entry into Force

1. This Agreement shall be open for signature at the depositary referred to in paragraph 2 below by the People's Republic of Bangladesh, Brunei Darussalam, the Kingdom of Cambodia, the People's Republic of China, the Republic of India, the Republic of Indonesia, Japan, the Republic of Korea, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Democratic Socialist Republic of Sri Lanka, the Kingdom of Thailand, the Socialist Republic of Viet Nam.

2. The Government of Singapore is the depositary of this Agreement.

3. This Agreement shall enter into force 90 days after the date on which the tenth instrument of notification by a State listed in paragraph 1, indicating the completion of its domestic requirements, is submitted to the depositary. Subsequently i. shall enter into force in respect of any other State listed in paragraph 1 above 30 days after its deposit of an instrument of notification to the depositary.

4. The depositary shall notify all the States listed in paragraph 1 of the entry into force of this Agreement pursuant to paragraph 3 of this Article.

5. After this Agreement has entered into force, it shall be open for accession by any State not listed in paragraph 1. Any State desiring to accede to this Agreement may so notify the depositary, which shall promptly circulate the receipt of such notification to all other Contracting Parties. In the absence of a written objection by a Contracting Party within 90 days of the receipt of such notification by the depositary, that State may deposit an instrument of accession with the depositary, and become a party to this Agreement 60 days after such deposit of instrument of accession.

Article 19
Amendment

1. Any Contracting Party may propose an amendment to this Agreement, any time after the Agreement enters into force. Such amendment shall be adopted with the consent of all Contracting Parties.

2. Any amendment shall enter into force 90 days after the acceptance by all Contracting Parties. The instruments of acceptance shall be deposited with the depositary, which shall promptly notify all other Contracting Parties of the deposit of such instruments.

Article 20
Withdrawal

1. Any Contracting Party may withdraw from this Agreement at any time after the date of its entry into force.

2. The withdrawal shall be notified by an instrument of withdrawal to the depositary.

3. The withdrawal shall take effect 180 days after the receipt of the instrument of withdrawal by the depositary.

The depositary shall promptly notify all other Contracting Parties of any withdrawal.

Article 21
Authentic Text

This Agreement shall be authentic in the English language.

## Article 22
## Registration

This Agreement shall be registered by the depositary pursuant to Article 102 of the Charter of the United Nations.

IN WITNESS WHEREOF, the undersigned, being duly authorized thereto by their respective Governments, have signed this Agreement.

For the Lao People's Democratic Republic:

**Done Somvorachit**
Ambassador Extraordinary and Plenipotentiary

For Japan:

**Ichiro Aisawa**
Senior Vice-Minister for Foreign Affairs

For the Republic of Singapore:

**Raymond Lim**
Acting Minister for Foreign Affairs

For the Kingdom of Cambodia:

**Kem Mongkol**
Ambassador Extraordinary and Plenipotentiary

Certified ~~true signature/ true document~~/true copy

Usha Devi Kannan

3 MAY 2005

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា )

ប្រោសព្រះរាជទាន

ចំពោះ

លោក **Fumiaki TAKAHASHI**

នូវ

គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧.ល.០៦០៤.១៥៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៦

លេខៈ ១៥២ . ច.ល
ដើម្បីប្រមូលចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែមេសា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៤៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក **យ៉ាង អ៊ីនឆាង** ( YANG YINCHANG ) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ១៩៦៣ នៅខេត្ត គុយចូវ ប្រទេសចិន ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខៈ ១៤៨.ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

៣៧៧-០៦០៤-១៥៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០០៦

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៥២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

